ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ)

ECONOMIC, SOCIAL AND CULTURAL COUNCIL (ECOSOCC)





# វិភាគស្ថានភាព
# សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ប្រចាំខែមករា ២០២០

# វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា
# ប្រចាំខែមករា ឆ្នាំ២០២០*

របាយការណ៍វិភាគនេះជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់(តារាង១)

➡ នាខែមករា ឆ្នាំ២០២០សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៥% ធៀបនឹងខែមុននិង កើនឡើង៣,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៦,៧% | ប្រេងសាំង | +១៤,១% |
| ការដឹកជញ្ជូន | +៤,៧% | ប្រេងម៉ាស៊ូត | +១៣,០% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៤,១% | ឧស្ម័ន: | +៨,៣% |
| ម្ហូបអាហារ: | +៤,០% | ត្រីស្រស់: | +៧,៣% |
| ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | +៣,៩% | ផ្លែឈើ: | +៤,៤% |
| សំលៀកបំពាក់ និងស្បែកជើង: | +៣,០% | អង្ករ: | +៣,៨% |
| ការសិក្សា: | +២,៧% | សាច់មាន់: | +៣,១% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +២,៦% | សាច់គោ: | +២,៧% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត: | +១,៨% | | |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +០,៧% | | |
| សុខាភិបាល: | +០,២% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៨–២០២០

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ P | មីនា P | មេសា P | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២០ | ដូចគ្នាឆ្នាំមុន | ៣,៦% | ២.៨% | ២,៦% | ២,៤% | | | | | | | | | |
| | មុន | ០,៥% | ០,១% | ០,០% | ០,១% | | | | | | | | | |
| ២០១៩ | ដូចគ្នាឆ្នាំមុន | ១,៥% | ២,០% | ២,២% | ២,១% | ២,០% | ១,៤% | ២,២% | ២,១% | ១,៧% | ១,៣% | ១,៨% | ៣,១% | ១,៩% |
| | មុន | -០,០២% | ០,៨% | ០,៣% | ០,៣% | ០,២% | -០,៤% | ០,៥% | ០,៦% | -០,០៣% | -០,១% | ០,១% | ០,៨% | |
| ២០១៨ | ដូចគ្នាឆ្នាំមុន | ២,០% | ២,៣% | ២,៣% | ២,៤% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ៣,១% | ២,៥% | ១,៦% | ២,៥% |
| | មុន | ០,១% | ០,៤% | ០,០៤% | ០,៥% | ០,៣% | ០,១% | -០,៣% | ០,៧% | ០,៣% | ០,៣% | -០,៣% | ០,១% | |

**P:** តួលេខខែកុម្ភៈ មីនា និងខែមេសា ២០២០ ជាតួលេខព្យាករណ៍ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | *មករា* ២០២០ | *ធ្នូ* ២០១៩ | *មករា* ២០១៩ | *ប្រភេទ* | *មករា* ២០២០ | *ធ្នូ* ២០១៩ | *មករា* ២០១៩ |
|---|---|---|---|---|---|---|---|
| **រ/ដុល្លារ** | ៤០៥០រ/១$ | ៤០៧៥រ/១$ | ៤០១១រ/១$ | **បាត/ដុល្លារ** | ៣១,១៦បាត/១$ | ២៩,៩៦បាត/១$ | ៣១,៣១បាត/១$ |
| **រ/បាត** | ១៣០រ/១បាត | ១៣៦រ/១បាត | ១២៨រ/១បាត | **ដុង/ដុល្លារ** | ២៣១៧៩ដុង/១$ | ២៣១៧១ដុង/១$ | ២៣២០២ដុង/១$ |
| **រ/ដុង** | ០,១៧៥រ/១ដុង | ០,១៧៦រ/១ដុង | ០,១៧៣រ/១ដុង | **យ៉ន់/ដុល្លារ** | ៦,៩១ យ៉ន់/១$ | ៦,៩៩ យ៉ន់/១$ | ៦,៧២ យ៉ន់/១$ |

## ២. ស្ថានភាពថវិកាជាតិ(តារាង២)

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមករា ឆ្នាំ២០២០ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ១ ៦៥៩,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤១៥,០ លានដុល្លារ (*មធ្យមប្រចាំខែ ៨១,៨% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ១ ៦៥៩,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៤១៥,០ លានដុល្លារ (*មធ្យមប្រចាំខែ ៨៣,៣% នៃផែនការ*) និងមិនមានចំណូលមូលធនទេ។

➢ ចំណូលថវិកាជាតិ ថយចុះ៥៧,៣% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង១០,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១ ៤៧១,៨ ប៊ីលានរៀល ថយចុះ៥០,៧% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង៣,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខរតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន ១៨៨,១ ប៊ីលានរៀលថយចុះ៧២,៤% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង១៦០,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខរតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៨-២០២០

(ប៊ីលានរៀល)



តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

| ចំណូលសារពើពន្ធ (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ចំណូលមិនមែនសារពើពន្ធ (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :-១,៥% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+១០,៣%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -៧១,៨% | (កើនកំហុត) |
| | | ➢ ផលទុននៃសកម្មភាពទេសចរណ៍: -៤៦,២% | (-៩,៤%) |
| ➢ ចំណូលពន្ធដារ: -៥៧,៥% (អគ្គនាយកដ្ឋានពន្ធដារ) | (+០,១%) | ➢សម្បទានរ៉ែ: -១៨,០% | (+៦២,៨%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: -៧៥,៦% | (+៤៣,៧%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ៨៨៩,០ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២២២,២ លានដុល្លារ(*មធ្យមប្រចាំខែ ៣៤,៣% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៨៤១,៦ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២១០,៤ លានដុល្លារ (*មធ្យមប្រចាំខែ ៥៦,០% នៃផែនការ*) និងចំណាយមូលធនមានចំនួន ៤៧,៣ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១១,៨ លានដុល្លារ(*មធ្យមប្រចាំខែ ៤,៣% នៃផែនការ*) (តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ៦៨,២% ធៀបនឹងខែមុននិង ថយចុះ១០,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្ត ថយចុះ៤៦,២% ធៀបនឹងខែមុននិង ថយចុះ១៣,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះ មាន អតិរេកចំនួន ៧៧០,៩ ប៊ីលានរៀល គិតជា ដុល្លារ អាមេរិក ស្មើ ១៩២,៧ លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៧-២០១៩

(ប៊ីលានរៀល)




## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់ (តារាង៣)

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមករា ឆ្នាំ២០២០ មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន ១០៥ ៧៧៥ ប៊ីលានរៀល មានការកើនឡើង១,៤%ធៀបនឹងខែមុននិងកើនឡើង ១៧,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង$M_2$** ក្នុងខែនេះ ជារួមបណ្ដាលមកពី ការកើនឡើងនៃ រូបិយវត្ថុក្រៅធនាគារ៤,០% ប្រាក់បញ្ញើចរន្ត៨,៤% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ៤,១% និងប្រាក់បញ្ញើជារូបិយបណ្ណ ០,៨%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែមករា ឆ្នាំ២០២០



➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៧,៩% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨២,១% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២០

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៧,៩% | | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៩% | | | | | | | | | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨២,១% | | | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែមករា ២០២០: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ៣៦ ៦៨៩ ប៊ីលានរៀលមានការ កើនឡើង ១,៨% ធៀបនឹងខែមុន និងកើនឡើង១៤,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *មករា ២០២០* | *ធ្នូ ២០១៩* | *មករា ២០១៩* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ: ជារៀល | ១០៨ ៩០០ | ១០៧ ៥៩៤<br>១០ ៩៦២ | ៨៩ ១៨៨<br>៣ ៨១៥ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ២៩ ៣៥៧ | ២២ ៦៣០ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៤,៥៩% | ៤,១០% | ៤,៥៤% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,៧០% | ៣,៤៤% | ៣,០៩% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១០,៦៤% | ៨,៥៩% | ១២,៤៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,១៨% | ៧,៩៧% | ៨,៣៤% |
| កម្ចីជារៀលនៅហត្ថកសិករ | ១៨,០% | ១៧,៨% | ១៧,៩% |
| កម្ចីជារៀលនៅអម្រឹត | ១៨,០% | ១៨,០% | ១៧,៩% |
| កម្ចីជារៀលនៅប្រាសាក់ | ១៧,០% | ១៦,១% | ១៦,២% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌ (តារាង៤)

➡ក្នុងខែមករា ឆ្នាំ២០២០ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន ៥២,០ ពាន់តោន ថយចុះ៥៤,៦% ធៀបនឹងខែមុននិង ថយចុះ៣,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢រ៉ែ និងថាមពល:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១០១២,២ GWh មានការកើនឡើង៦,០%ធៀបនឹងខែមុននិង កើនឡើង១៥,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

- អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៧១,៩ GWh មានការថយចុះ៥១,០% ធៀបនឹងខែមុន និងថយចុះ៥៧,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ៤១៨,៩ GWh មានការកើនឡើង១៤,១% ធៀបនឹងខែមុន និងកើនឡើង៩,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន៤២៣,៨ GWh មានការកើនឡើង២៦,៧%ធៀបនឹងខែមុននិង កើនឡើង៨៣,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ៩៧,៦ GWh មានការថយចុះ៨,៣% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៨,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ឧស្សាហកម្ម:

តារាង៤.១. ការចុះបញ្ជីរោងចក្រនិងឧស្សាហកម្មធុនតូច និងសិប្បកម្មនៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន — មករា ២០២០ | ចំនួន— ធ្នូ ២០១៩ | ចំនួន— មករា ២០១៩ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៣៦ | ២២ | ៣២ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៧៦៤ | ១៧៣០ | ១ ៥៤៥ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៣ | ២ | ៤ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៤ | ១ | ៣ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១ ៨៧៤,៣ ពាន់ម² មានការថយចុះ៦០,៣ ធៀបនឹងខែមុន និងថយចុះ១១,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ៨៦៩,១ លានដុល្លារមានការថយចុះ៥៨,៣ ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៤,៨% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² — មករា ២០២០ | ពាន់ម² — ធ្នូ ២០១៩ | ពាន់ម² — មករា ២០១៩ |
|---|---|---|---|
| ▪ លំនៅឋាន | ៧៥៤,៧ | ២ ៥៩៦,៩ | ១ ៨៨៤,៣ |
| ▪ ឧស្សាហកម្ម | ២៨៤,៨ | ៤១៨,៥ | ៨៤,៥ |
| ▪ពាណិជ្ជកម្ម | ៧៦៩,៦ | ១ ៣៩០,១ | ៨២,៦ |
| ▪ ទេសចរណ៍ | ៥៣,៨ | ២៩៨,៦ | ២៩,៣ |
| ▪ផ្សេងៗ | ០,០ | ០,៥ | ០,០ |
| អនុញ្ញាតសរុប | ១ ៨៧៤,៣ | ៤ ៧១៦,៥ | ២ ១១៨,៥ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺពាណិជ្ជកម្ម ៤១,១% និងលំនៅឋាន ៤០,៣% នៃផ្ទៃក្រឡាសរុប។

➢**សេវាកម្ម**

តារាង៤.៣.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន — មករា ២០២០ | ចំនួន— ធ្នូ ២០១៩ | ចំនួន— មករា ២០១៩ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៦៨២ | ៥៦១ | ១ ៤៣៤ |

| | | | |
|---|---|---|---|
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ២៧ ៥៤៧ | ៣១ ៩២៤ | ១១ ៥៧៨ |

➢**ការងារ**

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| *ប្រភេទ* | *នាក់– មករា ២០២០* | *នាក់– ធ្នូ២០១៩* | *នាក់– មករា ២០១៩* |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១ ១៩៧ | ៩៣១ | ១ ៧២៥ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ២១ ៤៤៥ | ២០ ៨៣៣ | ១៧ ៩៨៤ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៦ ៩៧៦ | ១៥ ៣៤៥ | ១៣ ១៤៣ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤ ៤៦៩ | ៥ ៤៨៨ | ៤ ៨៤១ |

➢**វិនិយោគ**

តារាង៤.៥.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| *ប្រភេទ* | *មករា ២០២០* | *ធ្នូ ២០១៩* | *មករា ២០១៩* |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៩២,៧ | ២ ១៣៣,៦ | ៣៧២,១ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០,០ | ៩០,៧ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៩២,៧ (៤៦,០) | ៩៨,៧ (២០,៨) | ៣៧២,១ (២៩០,៨) |
| វិស័យទេសចរណ៍ | ០,០ | ១៥១២,៧ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០,០ | ៤៣១,៦ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៧ | ៣១ | ៣២ |
| បង្កើតការងារ (ពាន់នាក់) | ១២,២ | ៣២,៩ | ៣៤,៥ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន ៩៩៧,៩ ពាន់តោន មានការកើនឡើង៤,៤% ធៀបនឹងខែមុននិងកើនឡើង១៥,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ: +៥,៩% (+១២,០%) | ▪ កំពង់ផែកំពង់សោម: +៣,៦% (+១៧,៣%) |

➢**ការចុះបញ្ជី និងចរាចរណ៍**

តារាង៤.៧.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| *ប្រភេទ* | *ចំនួន –មករា ២០២០* | *ចំនួន–ធ្នូ ២០១៩* | *ចំនួន–មករា ២០១៩* |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៤២,៨ | ៥១,៨ | ៥៧,៣ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ១១,២ | ៦,៨ | ១៣,៧ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ៣៥៨ | ៣៧៣ | ៣៣១ |

➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ២៥,៥ | -០,៤% | +១៦,៣% |
| ក្នុងនោះទទួល | ២,៦ | -២,៧% | -៣,៥% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៩៩,០ | -១១,៨% | -៩,៥% |
| ក្នុងនោះទទួល | ៥៣,០ | -៩,២% | -៤,០% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១ ២៥០,៧ | -២៨,៧២% | -២៨,៦៨% |
| ក្នុងនោះហៅចូល | ៤៣៨,៦ | -៤៨,២% | -១៥,១% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៤ ២២៥,៧ | -៧,៥៨% | -៤១,៥៧% |
| ក្នុងនោះហៅចូល | ៤ ១៨១,១ | -៧,៦៤% | -៤១,៦០% |

➢ ធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២២,៤ | +២៤,៨% | -២,០% |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ២២២,៦ | +៦,៨% | -១៧,៩% |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ១០,០ | +៣៧,៥% | +០,៧% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១២៨,២ | +៣,៥% | +១,១% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៨៧៧,៤ | +១,៤% | -១០,៣% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៥២,៤ | -៨,១% | -១,២% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៥៤៨,០ | -២៣,១% | -១៥,៣% |
| ✓ តាមផ្លូវអាកាស | ៣៣២,១ | -៥,៩% | -១៧,៧% |
| ✓ តាមផ្លូវគោក និងទឹក | ២១៥,៨ | -៤០,០% | -១១,៥% |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម(តារាង៥)

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមករា ឆ្នាំ២០២០ មានចំនួន ៨ ០១៥,៦ ប៊ីលានរៀល (ស្មើនឹង ២ ០០៣,៩ លានដុល្លារ ស.រ.អា.)កើនឡើង១២,១% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង២៣,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +២៨,៣% | +២១,៩% | រថយន្តសរុប (ប៊ី.ល.រ) | -១៥,៨% | +១៧,១% |
| ប្រេងម៉ាស៊ូត | -២០,៩% | -១,០% | រថយន្តសរុប (គ្រឿង) | -២១,១% | -០,៩% |
| ឧស្ម័ន | -៥០,៧% | -២០,៨% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -៤៥,៩% | -៣២,០% |
| អគ្គិសនីនាំចូលដោយEDC | +២៦,៧% | +៨៣,៩% | ម៉ូតូ (គ្រឿង) | -១៩,២% | -៩,៨% |
| ដែកសំណង់ | -៦,៣% | -៣៧,៨% | អង្ករ | +៦៨,៦% | -៦១,៩% |
| ស៊ីម៉ង់ត៍ | -១៣,៩% | +៨,៨% | ផ្លែឈើនិងបន្លែ | +៣៤៦,៣% | +៣២៩,៨% |
| គ្រឿងអេឡិចត្រូនិក | -៥៥,៣% | +២២,០% | ថ្នាំកសិកម្ម | -១៣,០% | +២៦,១% |
| ជីកសិកម្ម | -៤៦,៣% | -៧៧,៧% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +១៧,៩% | +៨,៣% |

➡ **ការនាំចេញ** ខែមករា ឆ្នាំ២០២០ មានចំនួន **៥ ២៩៥,១** ប៊ីលានរៀល ស្មើនឹង **១ ៣២៣,៨** លានដុល្លារ ស.រ.អា. (៦៦,១% នៃការនាំចូល) មានការកើនឡើង៥,៤% ធៀបនឹងខែមុន និងកើនឡើង២៣,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១០២,៩% | -៣៨,៤% | ផលិតផលនេសាទ | +១២,៤% | +១,២% |
| វាយនភណ្ឌនិងស្បែកជើង | +១៩,២% | +២៥,២% | កៅស៊ូ | -៥៣,៥% | -៣០,៩% |
| អង្ករ | -៤,៥% | +២២,៩% | | | |

# ក្រុមការងាររៀបចំរបាយការណ៍ស្តីពីស្ថានភាព
# សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌



អាស័យដ្ឋានៈ ៨១ មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌ៧មករា រាជធានីភ្នំពេញ

**ទូរស័ព្ទៈ 085 777 940 ទូរសារៈ 023 221 440**

**Email: chyanit168@gmail.com / mamsarith@yahoo.com**